# កិច្ចព្រមព្រៀង
# រវាង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលរដ្ឋគុយវ៉ែត
# ស្តីពី
# ការលើកលែងទិដ្ឋាការសំរាប់អ្នកកាន់លិខិតឆ្លងដែនការទូត ពិសេស និងផ្លូវការ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគុយវ៉ែត អំណឹះតទៅហៅថា "ភាគី"។

ដោយមានបំណងពង្រឹងទំនាក់ទំនងជាមិត្តភាពរវាងប្រទេសទាំងពីរ។

ដោយចង់សំរួលដល់ការធ្វើដំណើរចូល-ចេញនៃអ្នកកាន់លិខិតឆ្លងដែនការទូត ពិសេស និងផ្លូវការរបស់ប្រទេសទាំងពីរ។

បានព្រមព្រៀងគ្នាដូចតទៅ៖

## មាត្រា ១

រាល់បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះអ្នកកាន់លិខិតឆ្លងដែនតាមប្រភេទដូចតទៅ៖

១- សំរាប់ព្រះរាជាណាចក្រកម្ពុជាៈ លិខិតឆ្លងដែនការទូត និងផ្លូវការ។

២- សំរាប់រដ្ឋគុយវ៉ែតៈ លិខិតឆ្លងដែនការទូត និងពិសេស។

## មាត្រា ២

១- ពលរដ្ឋនៃភាគីទាំងពីរដែលកាន់លិខិតឆ្លងដែនដែលមានចែងក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀងនេះ អាចចូល-ចេញ ឆ្លងកាត់ និងស្នាក់នៅ ក្នុងទឹកដីនៃភាគីម្ខាងទៀតដោយគ្មានទិដ្ឋាការក្នុងរយៈពេលមិនលើសពី ៣០ (សាមសិប)ថ្ងៃ ចាប់ពីថ្ងៃចូល។

២- ការពន្យាពេលស្នាក់នៅដែលមានចែងក្នុងកថាខ័ណ្ឌទី ១ ត្រូវអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះតាមសំណើជាលាយលក្ខអក្សររបស់ស្ថានបេសសកម្មការទូត ឬកុងស៊ុលនៃរដ្ឋដាក់ទូត។

៣- ក្នុងករណីគ្មានស្ថានបេសសកម្មការទូត ឬបុស្តិ៍កុងស៊ុលរបស់រដ្ឋដាក់ទូតនៅក្នុងរដ្ឋម្ចាស់ផ្ទះទេនោះ អ្នកកាន់លិខិតឆ្លងដែនការទូត ពិសេស និងផ្លូវការ ត្រូវស្នើសុំទៅនាយកដ្ឋានកុងស៊ុលនៃក្រសួងការបរទេស នៃរដ្ឋម្ចាស់ផ្ទះ។

## មាត្រា ៣

ពលរដ្ឋនៃភាគីម្ខាងកាន់លិខិតឆ្លងដែនដូចមានចែងក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀងនេះ និងដែលជាសមាជិកនៃស្ថានបេសសកម្មការទូត ស្ថានកុងស៊ុល រឺក៏តំណាងផ្លូវការរបស់អង្គការអន្តរជាតិប្រចាំនៅក្នុងទឹកដីនៃភាគីម្ខាងទៀត រួមទាំងក្រុមគ្រួសាររស់នៅជាមួយ ដែលកាន់លិខិតឆ្លងដែនដូចមានចែងនៅក្នុងមាត្រា ១ ដែរនោះ អាចចូល-ចេញ ឆ្លងកាត់ និងស្នាក់នៅលើទឹកដីនៃភាគីម្ខាងទៀតក្នុងកំឡុងពេលបំពេញការងារដោយមិនតំរូវឲ្យមានទិដ្ឋាការឡើយ ហើយពួកគេត្រូវអនុវត្តតាមតំរូវការចូល-ចេញ ស្នាក់នៅរបស់ភាគីម្ខាងទៀតក្នុងកំឡុងពេល ៣០ (សាមសិប)ថ្ងៃ មុនពេលមកដល់ក្នុងទឹកដីនៃភាគីនោះ។

## មាត្រា ៤

ពលរដ្ឋដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះអាចចូល-ចេញ ឆ្លងកាត់ក្នុងទឹកដីនៃភាគីម្ខាងទៀត តាមគ្រប់ច្រកព្រំដែនដែលបើកឲ្យចរាចរណ៍ជាអន្តរជាតិ។

## មាត្រា ៥

ពលរដ្ឋនៃភាគីទាំងពីរដែលកាន់លិខិតឆ្លងដែនដូចមានចែងក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀងនេះត្រូវគោរពច្បាប់ និងបទបញ្ញត្តិជាធរមាននៃរដ្ឋម្ចាស់ផ្ទះក្នុងកំឡុងពេលស្នាក់នៅក្នុងរដ្ឋនោះ។

## មាត្រា ៦

ភាគីនីមួយៗរក្សាសិទ្ធិបដិសេធការចូល ឬបញ្ចប់ការស្នាក់នៅចំពោះបុគ្គលមិនជាទីស្វាគមន៍ដោយពុំចាំបាច់បញ្ជាក់ពីមូលហេតុ។

## មាត្រា ៧

១- ភាគីទាំងពីរត្រូវផ្លាស់ប្ដូរគំរូលិខិតឆ្លងដែនដូចមានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងនេះតាមផ្លូវការទូតក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

២- ក្នុងករណីមានផ្លាស់ប្ដូរលិខិតឆ្លងដែនដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ភាគីទាំងពីរត្រូវជូនពត៌មាន និងផ្ដល់ឲ្យគ្នាទៅវិញទៅមកតាមផ្លូវការទូតនូវគំរូលិខិតឆ្លងដែនទាំងនេះរួមជាមួយពត៌មានលំអិតអំពីការអនុវត្តយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ មុនការចូលជាធរមាននៃការផ្លាស់ប្ដូរនោះ។

## មាត្រា ៨

ភាគីនីមួយៗអាចផ្អាកការអនុវត្តកិច្ចព្រមព្រៀងនេះទាំងស្រុង ឬដោយផ្នែកណាមួយ យោងលើហេតុផលសន្តិសុខ សណ្ដាប់សាធារណៈ ឬកិច្ចការពារសុខភាព។ ការផ្អាក និងការបន្តអនុវត្តឡើងវិញនៃកិច្ចព្រមព្រៀងនេះត្រូវជូនពត៌មានគ្នាទៅវិញទៅមកជាលាយលក្ខអក្សរតាមផ្លូវការទូត។

## មាត្រា ៩

ពល់វិវាទដែលកើតឡើងរវាងភាគីទាំងពីរទាក់ទងនឹងការបកស្រាយ ឬ ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយតាមរយៈការពិគ្រោះយោបល់ និងការចរចារវាងភាគីទាំងពីរ។

## មាត្រា ១០

កិច្ចព្រមព្រៀងនេះអាចធ្វើវិសោធនកម្ម និងបន្ថែមបានតាមការព្រមព្រៀងរវាងភាគីទាំងពីរ។ ការធ្វើវិសោធនកម្មនឹងចូលជាធរមានទៅតាមនីតិវិធីដូចមានចែងក្នុងមាត្រា ១១ នៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១១

កិច្ចព្រមព្រៀងនេះនៅជាធរមានគ្មានពេលកំណត់ ប្រសិនបើពុំមានភាគីណាមួយធ្វើការជំទាស់ជាលាយលក្ខអក្សរតាមផ្លូវការទូត។ ការជំទាស់នឹងចូលជាធរមាន ៩០ (កៅសិប)ថ្ងៃ បន្ទាប់ពីទទួលបាននូវលិខិតជូនដំណឹង។

## មាត្រា ១២

កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាននៅថ្ងៃដែលទទួលបានការជូនដំណឹងចុងក្រោយដោយភាគីម្ខាងជាលាយលក្ខអក្សរតាមផ្លូវការទូតអំពីការបំពេញចប់សព្វគ្រប់នីតិវិធីផ្ទៃក្នុងសំរាប់ការចូលជាធរមាន។

ធ្វើនៅ ភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤ ជាពីរច្បាប់ដើម ជាភាសាខ្មែរ អារ៉ាប់ និងអង់គ្លេស ដែលអត្ថបទនីមួយៗមានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកជាឯកសារគោល។

| | |
|---|---|
| ជ.រដ្ឋាភិបាល<br>នៃព្រះរាជាណាចក្រកម្ពុជា | ជ.រដ្ឋាភិបាល<br>នៃរដ្ឋគុយវ៉ែត |
| ឡុង វិសាលោ<br>រដ្ឋលេខាធិការ នៃក្រសួងការបរទេស<br>និងសហប្រតិបត្តិការអន្តរជាតិ | ដេរ៉ា អាល់ ទូវ៉ៃជ្រី<br>ឯកអគ្គរាជទូតនៃរដ្ឋគុយវ៉ែត<br>ប្រចាំព្រះរាជាណាចក្រកម្ពុជា |